# មេរៀនទី ២០៖ សុលជួបព្រះយេស៊ូវ

## [កិច្ចការ ៩៖១-២០]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/gTj_JuXF9vQ

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/4uFNHpvvNng

**គោលបំណង៖** ព្រះយេស៊ូវធ្វើការអស្ចារ្យជាច្រើន

**ខគម្ពីរចងចាំ៖**
**ទំនុកដំកើង ១២៦៖៣** *"ព្រះយេហូវ៉ាបានធ្វើការយ៉ាងធំសំរាប់យើងមែនហើយក៏អរណាស់ដែរ"។*

**ចំរៀង** ( *យូធូបលីង* )៖
១. ព្រះយេស៊ូវគឺជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo
២. ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ
៣. ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត « ព្រះយេស៊ូវទ្រង់អស្ចារ្យ »




សម្ភារៈដែលត្រូវការ៖ ក្រដាស និង ប៊ិកសម្រាប់សរសេរ

១.ចែកសិស្សជា ២ ក្រុម ហើយឲ្យក្រដាស និងប៊ិកទៅក្រុមនីមួយៗ

២.ឲ្យកុមារសរសេរពីការអស្ចារ្យរបស់ព្រះយេស៊ូវនៅលើក្រដាសនោះ។ ទុកពេលឲ្យកុមាររយៈពេលប្រហែលជា ៥ នាទី

៣.ក្រុមនីមួយៗនឹងក្រោកឈរអាននូវការអស្ចារ្យរបស់ព្រះយេស៊ូវ ដែលក្រុមរបស់ពួកគេបានសរសេរ។

៤.ក្រុមណាដែលសរសេរពីការអស្ចារ្យរបស់ព្រះយេស៊ូវ បានច្រើនជាងគេ គឺជាអ្នកឈ្នះ។

៥.សូមពន្យល់ទៅកុមារថា ព្រះយេស៊ូវទ្រង់អស្ចារ្យ ហើយទ្រង់នៅតែធ្វើការអស្ចារ្យរហូតដល់សព្វថ្ងៃនេះ!

### ៤. ការណែនាំមេរៀន

នៅក្នុងព្រះគម្ពីរព្រះយេស៊ូវបានធ្វើការអស្ចារ្យច្រើនជាងនេះទៅទៀត! តើអ្នកអាចគិតឃើញអំពីការអស្ចារ្យមួយ ចំនួនដែលព្រះយេស៊ូវបានធ្វើក្នុងព្រះគម្ពីរទេ? (ទុកឱ្យកុមារឆ្លើយ-ធ្វើឱ្យបុរសពិការភ្នែកមើលឃើញវិញ, ធ្វើឲ្យមនុស្សស្លាប់រស់ឡើងវិញ, ផ្តល់អាហារដល់មនុស្ស ៥០០០ នាក់ ជាមួយនឹងនំបុ័ង ៥ដុំ និងត្រី ២ កន្ទុយ។ ល។ ) ។ តើអ្នកជឿថាព្រះយេស៊ូវនៅតែអាចធ្វើរឿងអស្ចារ្យនៅក្នុងជីវិតរបស់អ្នកបានដែរឬទេ? នៅពេលដែលព្រះយេស៊ូវចូលក្នុងជីវិតរបស់អ្នក រឿងដ៏អស្ចារ្យអាចកើតឡើងបាន។ ថ្ងៃនេះយើងនឹងរៀនអំពីបុរសម្នាក់ ដែលជីវិតរបស់គាត់បានផ្លាស់ប្តូរយ៉ាងអស្ចារ្យបន្ទាប់ពីគាត់បានជួបព្រះយេស៊ូវ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនេះដកស្រង់ចេញពីព្រះគម្ពីរកិច្ចការ។ មានបុរសម្នាក់ឈ្មោះ សុល ជាមនុស្សឆ្លាត ហើយមានអំណាច។ ប៉ុន្តែគាត់ក៏សាហាវណាស់ដែរ។ សុលមិនបានជឿលើព្រះយេស៊ូវទេ ហើយគាត់ចង់ឲ្យមនុស្សដែលជឿលើព្រះយេស៊ូវឈប់ជឿព្រះយេស៊ូវទៀត។ នៅថ្ងៃមួយ សុលបានទៅទីក្រុងមួយមានឈ្មោះថា ក្រុងដាម៉ាស ដើម្បីស្វែងរកចាប់អ្នកដែលជឿលើព្រះយេស៊ូវ ហើយបញ្ជូនពួកគេទៅដាក់គុក។ ព្រះយេស៊ូវពិបាកព្រះទ័យណាស់ដោយសារគាត់ដឹងថាសុលចង់ធ្វើបាបប្រជាជនទាំងនោះ។

ភ្លាមៗនោះមានរឿងអស្ចារ្យមួយបានកើតឡើង! ពន្លឺដ៏ចាំងចែងពីស្ថានសួគ៌បានមកនៅជុំវិញសុល។ **កិច្ចការ ៩៖៤-៦** “ គាត់ក៏ដួលដល់ដី រួចឮសំឡេងមានព្រះបន្ទូលមកថា សុល នៃសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ គាត់ទូលឆ្លើយថា ឱព្រះអម្ចាស់អើយ ព្រះអង្គណាន៎ះ រួច ព្រះអម្ចាស់ទ្រង់តបថា ខ្ញុំនេះជាព្រះយេស៊ូវ ដែលអ្នកបៀតបៀន អ្នកធាក់ដល់នឹងជន្លួញដូច្នេះ នោះពិបាកដល់អ្នកណាស់ នោះគាត់ក៏ញាប់ញ័រ ទាំងអស្ចារ្យក្នុងចិត្ត ហើយទូលថា ព្រះអម្ចាស់ អើយ តើទ្រង់សព្វព្រះហឫទ័យឲ្យទូលបង្គំធ្វើដូចម្តេច ព្រះអម្ចាស់មានព្រះបន្ទូលថា ចូរក្រោក ឡើងចូលទៅក្នុងទីក្រុងទៅ នោះគេនឹង ប្រាប់អ្នកឲ្យដឹងពីការដែលអ្នកត្រូវធ្វើ” ។ ដូច្នេះ សុលក៏ ក្រោកពីដី ពេលគាត់បើកភ្នែក មានរឿងដ៏អស្ចារ្យមួយទៀតបានកើតឡើង។ គាត់មើលមិនឃើញ! ដូច្នេះ មិត្តរបស់គាត់បាននាំគាត់ចូលទៅក្នុងទីក្រុង ដោយគោរពតាមសំឡេងពីស្ថានសួគ៌។ សុល ពិការភ្នែក អស់បីថ្ងៃ។

បន្ទាប់មក ព្រះយេស៊ូវចាត់បុរសម្នាក់ឈ្មោះអាណានាសឲ្យទៅប្រាប់សុលអំពីព្រះយេស៊ូវ។ ពេលសុលបានឮអំពីព្រះយេស៊ូវ មានរឿងអស្ចារ្យមួយទៀតបានកើតឡើង! ភ្លាមៗនោះ សុលបានមើលឃើញម្តងទៀត! ដោយសារអ្វីដែលព្រះបានធ្វើ នោះសុលបានជឿលើព្រះយេស៊ូវ។ សុលត្រូវគេហៅថា ប៉ុល ហើយគាត់បានក្លាយជាមនុស្សដ៏អស្ចារ្យសម្រាប់ព្រះ។ តាមពិតប៉ុលបានសរសេរសៀវភៅ ១៣កណ្ឌ ក្នុងចំណោមសៀវភៅ ២៧កណ្ឌ នៃគម្ពីរសញ្ញាថ្មី។ ពិតជាអស្ចារ្យមែន!

## ៦. សំនួរពិភាក្សា

១. តើសាច់រឿងនៅថ្ងៃនេះបានដកស្រង់ចេញពីកណ្ឌគម្ពីរមួយណា? *(កិច្ចការ)*

២. ហេតុអ្វីបានជាសុលទៅក្រុងដាម៉ាស?
*(ដើម្បីស្វែងរកមនុស្សដែលជឿលើព្រះយេស៊ូវ ហើយចាប់ពួកគេដាក់ក្នុងគុក)*

៣.តើមានអ្វីកើតឡើងចំពោះគាត់នៅតាមផ្លូវទៅទីក្រុងដាម៉ាស? *(ពន្លឺដ៏ខ្លាំងបានជះមកលើគាត់ គាត់បានឮសំឡេងរបស់ព្រះយេស៊ូវបានសួរគាត់ហេតុអ្វីបានជាគាត់បៀតបៀនព្រះយេស៊ូវ ហើយភ្នែកគាត់ក៏ងងឹត)*

៤. តើពេលណាទើបគាត់អាចមើលឃើញម្តងទៀតបាន? *(៣ថ្ងៃក្រោយ ពេលអាណានាសមកប្រាប់សុលអំពីព្រះយេស៊ូវ)*

៥. តើជីវិតរបស់ប៉ុលបានក្លាយទៅជាអស្ចារ្យយ៉ាងណា? *(គាត់បានក្លាយជាមនុស្សដ៏អស្ចារ្យសម្រាប់ព្រះ ហើយបានសរសេរកណ្ឌគម្ពីរចំនួន ១៣កណ្ឌ ក្នុងចំណោម ២៧កណ្ឌ នៃគម្ពីរសញ្ញាថ្មី)*

៦. តើព្រះបានធ្វើរឿងអស្ចារ្យអ្វីខ្លះក្នុងជីវិតរបស់អ្នក? *( សូមឲ្យកុមារឆ្លើយ គ្រូអាចចែកចាយទីបន្ទាល់អំពីបទពិសោធន៍របស់ពួកគេជាមួយនឹងព្រះ )*

៧.តើព្រះអាចធ្វើការអស្ចារ្យសំរាប់ប្អូនដូចជាសាវ័កប៉ុលបានដែរឬទេ?

## ៧. ល្បែងកំសាន្ត «ឃើញភ្លាមថាភ្លែត»

សម្ភារៈដែលត្រូវការ៖ សៀវភៅ បន្ទាត់ ដបទឹក ម៉ាស់ ខ្មៅដៃ ប៊ិក ខ្មៅដៃពណ៌ ។ល។ សម្ភារៈទាំងអស់ត្រូវតែដាក់ក្នុងថង់ខ្មៅ ឬថង់ដែលមិនអាចឃើញរបស់ ដែលនៅខាងក្នុងថង់បាន។



១.ចែកកុមារជាពីរក្រុម ហើយសុំឱ្យក្រុមនីមួយៗ ជ្រើសរើសអ្នកតំណាងម្នាក់ឱ្យឈរនៅទល់មុខគ្រូ។

២. ពេលគ្រូយករបស់អ្វីមួយចេញពីកក្នុងកាបូប កុមារត្រូវនិយាយឲ្យបានមុនគេថារបស់នោះជាអ្វី។ ក្រុមដែលឆ្លើយលឿនជាងគេក្រុមនោះជាអ្នកឈ្នះ ? (កុមារនៅក្នុងក្រុមនីមួយៗត្រូវប្តូរវេនគ្នាដើម្បីលេងរហូតដល់អស់សម្ភារៈនៅក្នុងថង់នោះ)

៣. គ្រូត្រូវបន្ថែមពិន្ទុសម្រាប់ក្រុមនីមួយៗ ហើយក្រុមដែលឈ្នះនឹងទទួលបានរង្វាន់។

## ៨. ខគម្ពីរចងចាំ

**ទំនុកដំកើង ១២៦៖៣** *"ព្រះយេហូវ៉ាបានធ្វើការយ៉ាងធំសំរាប់យើងមែនហើយក៏អរណាស់ដែរ"*។

## ៩. ហត្ថកម្ម « ផ្គុំរូបឈើឆ្កាង »

សម្ភារៈដែលត្រូវការ៖ បោះពុម្ពច្បាប់ចម្លងគ្រប់គ្រាន់នៃរូបផ្គុំឈើឆ្កាង (សូមមើលខាងក្រោមដើម្បីបោះពុម្ព) ហើយកាត់ចេញជាបំណែក។



១. ចែកកុមារជាក្រុមដែលមានគ្នាពី៣ទៅ៤នាក់ក្នុង១ក្រុម ហើយឲ្យបំណែកផ្គុំ ដែលកាត់ចេញនោះឲ្យពួកគាត់។

២. ប្រាប់កុមារឱ្យដាក់រូបផ្គុំជាមួយគ្នា ដើម្បីធ្វើចេញជាអ្វីដែលអស្ចារ្យ។

៣. បន្ទាប់ពីមើលក្មេងៗព្យាយាមរកមើលថាអ្វីដែលអស្ចារ្យអាចក្លាយចេញរូបផ្គុំបាន សូមប្រាប់ពួកគេថាពួកគេអាចប្រើរាងទាំងនេះដើម្បីធ្វើជាឈើឆ្កាងបាន!



៤. ក្រុមដំបូងដែលធ្វើឈើឆ្កាងរួចមុនគេគឺជាអ្នកឈ្នះ!

ពន្យល់ពួកគេថារបស់ដែលសាមញ្ញៗដូចជាទម្រង់ក្រដាសទាំងនេះ អាចត្រូវបានផ្គុំបញ្ចូលគ្នា ដើម្បីបង្កើតបានជារបស់ដ៏អស្ចារ្យបាន។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ប្រហែលជារបៀបដែលអ្នកជួបព្រះយេស៊ូវមិនអស្ចារ្យដូចជាលោកប៉ុលនោះទេ ប៉ុន្តែវាមិនអីនោះទេ។ អ្វីដែលសំខាន់នោះ គឺថាតើអ្នកបានដើរជាមួយព្រះអង្គបានច្រើនបំផុតដែរឬអត់។ សូមបិទភ្នែករបស់អ្នក ហើយសញ្ជឹងគិតឱ្យ អំពីមូលហេតុដែលអ្នកបានដាក់ក្តី សង្ឃឹមរបស់អ្នកនៅក្នុងព្រះគ្រីស្ទ។ សូមគិតអំពីមនុស្សម្នាក់ ដែលអ្នកអាចប្រាប់គេពីក្តីសង្ឃឹមរបស់អ្នកដែលបានរកឃើញនៅក្នុងព្រះគ្រីស្ទ ។ សូមអធិស្ឋានឲ្យព្រះធ្វើការតាមរយៈអ្នក ដើម្បីនាំបុគ្គលនោះមកក្នុងគ្រួសារនៃព្រះគ្រីស្ទ។

# ផ្គុំរូបឈើឆ្កាង





ឈើឆ្កាង
ដែលបានផ្គុំរួច



